# ខេត្តបាត់ដំបង
## សក្តានុពលវិនិយោគ

ខែ មករា ឆ្នាំ ២០១០

ជំនួយពីពលរដ្ឋអាមេរិក




# ខេត្តបាត់ដំបង
## ទីក្រុងដ៏មមាញឹកនៃភាគពាយព្យ









**បញ្ជាក់:**

ទស្សនៈរបស់អ្នកនិពន្ធដែលបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនឆ្លុះបញ្ចាំងអំពីទស្សនៈរបស់ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ ឬ រដ្ឋាភិបាលអាមេរិកឡើយ ។




# របាយការណ៍វិនិយោគនៅខេត្តបាត់ដំបង

**សុន្ទរកថាស្វាគមន៍របស់ឯកឧត្តមអភិបាលខេត្ត** ........ ២

**ចំណុចខ្លាំងថ្នាក់ជាតិ** ........ ៣

បើកចំហចំពោះអាជីវកម្ម

កំលាំងពលកម្មតម្លៃទាប និងមានផលិតភាព

ទីតាំងជាយុទ្ធសាស្ត្រក្នុងតំបន់

**ហេតុអ្វីវិនិយោគនៅខេត្តបាត់ដំបង?** ........ ៤

១. ទីតាំង - ទីក្រុងនៃភាគពាយព្យ

២. ដីមានជីជាតិបំផុតនៃប្រទេសកម្ពុជា

៣. ទីផ្សារធំជាងគេទីពីរនៅកម្ពុជា

៤. កម្លាំងពលកម្ម - ច្រើន មានវ័យក្មេង មានការអប់រំ មានតម្លៃពលកម្មទាប

៥. ការផ្គត់ផ្គង់អគ្គិសនីប្រកបដោយការប្រកួតប្រជែង

៦. ទេសចរណ៍

៧. ធនធានធម្មជាតិមិនទាន់ប្រើប្រាស់

**វិស័យសំខាន់ៗរបស់ខេត្ត** ........ ៧

**កាលានុវត្តភាពអាជីវកម្ម** ........ ៧

**សកម្មភាពអភិវឌ្ឍន៍កំពុងដំណើរការ** ........ ៨

**ត្រូវការស្វែងយល់បន្ថែមទៀតទេ?** ........ ៨

របាយការណ៍វិនិយោគនេះផលិតដោយ Emerging Markets Consulting សំរាប់ គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា ដែលអនុវត្តគំរោងដោយអង្គការ DAI ឧបត្ថម្ភថវិកាដោយ ទីភ្នាក់ងារសហរដ្ឋអាមេរិក ដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងមានការចូលរួមសហការពីសាលាខេត្តបាត់ដំបង និងគណៈកម្មាធិការវិនិយោគកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។








## សារស្វាគមន៍របស់ឯកឧត្តម អភិបាលខេត្ត

ក្នុងនាមរដ្ឋបាលខេត្តបាត់ដំបង ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និង ក្ដីសោមនស្សរីករាយឥតឧបមា សូមសំដែងនូវការស្វាគមន៍ ចំពោះ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោក នាងកញ្ញា និងប្រិយមិត្តទាំងអស់ ដែលបានយកចិត្ត ទុកដាក់ សិក្សាស្វែងយល់អំពីសក្ដានុពលក្នុងខេត្តបាត់ដំបង ជាពិសេស ទាក់ទងនឹងការវិនិយោគ និងកិច្ចការមួយចំនួនទៀតក្នុងសកម្មភាពសេដ្ឋកិច្ចសង្គម ។

ខ្ញុំសូមសំដែងនូវការដឹងគុណជាពិសេស ចំពោះទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ដែលជាម្ចាស់ជំនួយ គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា ហើយបានផ្ដួចផ្ដើមនិងឧបត្ថម្ភសម្រាប់ការផលិត កម្រងឯកសារស្ដីពីសក្ដានុពលវិនិយោគក្នុងខេត្តបាត់ដំបងនេះឡើង ។

កម្រងឯកសារដែលឆ្លុះបញ្ចាំងអំពី ស្ថានភាពទូទៅមួយចំនួនរបស់ខេត្ត និងទិន្នន័យចំបងៗព្រមទាំងព័ត៌មានពាក់ព័ន្ធនានា ពិតជាមានសារសំខាន់ សម្រាប់បម្រើដល់ការសិក្សាស្វែងយល់អំពីកាលានុវត្តភាពវិនិយោគ និងជាមូលដ្ឋានគ្រឹះក្នុងការទំនាក់ទំនង ផ្នែកធុរកិច្ចដទៃទៀត ។ ដោយឈរលើស្មារតីនៃកិច្ចសហប្រតិបត្តិការ បំណងប្រាថ្នា និងឆន្ទៈដ៏មុតស្រួចរបស់អាជ្ញាធរគ្រប់លំដាប់ព្រមទាំងប្រជាពលរដ្ឋទូទាំងខេត្តបាត់ដំបង យើងខ្ញុំសូមសំដែងនូវការស្វាគមន៍គាំទ្របើកចំហក្នុងអំណរសាទរលើកទឹកចិត្ត និងត្រៀមលក្ខណៈជានិច្ច ដើម្បីផ្ដល់កិច្ចសហការសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលគ្រប់បែបយ៉ាង តាមលទ្ធភាពដែលអាចធ្វើបានចំពោះគំនិតផ្ដួចផ្ដើមគម្រោងវិនិយោគ និងការអភិវឌ្ឍន៍នានាក្នុងខេត្តបាត់ដំបង ក្នុងទិសដៅលើកកម្ពស់ខឿនសេដ្ឋកិច្ច-សង្គម ជម្រុញកិច្ចអភិវឌ្ឍន៍ប្រកបដោយ ចិរភាព វឌ្ឍនភាព និងវិបុលភាពជាបណ្ដើរៗ សំដៅកាត់បន្ថយភាពក្រីក្រ ស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

យើងខ្ញុំទន្ទឹងរង់ចាំដោយក្ដីរីករាយនិងសូមស្វាគមន៍ចំពោះ ការចូលរួមមតិយោបល់ និងអនុសាសន៍បន្ថែមទៀតពីសំណាក់ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោកស្រី អស់លោក នាងកញ្ញា និងប្រិយមិត្តទាំងអស់ ។ ព័ត៌មានផ្សេងៗ សូមមើលគេហទំព័រសាលាខេត្តបាត់ដំបង www.battambang.gov.kh ឬទំនាក់ទំនងតាមទូរស័ព្ទនិងទូរសារលេខ 053 952 141 និងអ៊ីម៉ែល btbgovernor@camnet.com.kh ឬ monyveung@yahoo.com ។ សូមទទួលនូវការគោរពរាប់អានអំពីខ្ញុំ ។

បាត់ដំបង ខែ មករា ឆ្នាំ ២០១០

**អភិបាលខេត្តបាត់ដំបង**



**ឯកឧត្តម ប្រាជ្ញ ចន្ទ**





## ចំណុចខ្លាំងថ្នាក់ជាតិ

អស់រយៈពេលជាងមួយទសវត្សរ៍កន្លងទៅនេះ ប្រទេសកម្ពុជាបានលេចឡើងជាប្រទេសក្នុងតំបន់ដែលមានតួនាទីរស់រវើក និង រឹងមាំជាមួយនឹងកេតនភណ្ឌជាមូលដ្ឋានជាច្រើនដែលចាំបាច់សម្រាប់ការអភិវឌ្ឍន៍ និងកំណើនអាជីវកម្មដោយជោគជ័យ ។

### បើកចំហចំពោះអាជីវកម្ម

- ពន្ធអាជីវកម្មទាប - ពន្ធ ២០% លើផលចំណេញអាជីវកម្ម (អាចអនុគ្រោះពន្ធដល់ ៥ ឆ្នាំ ចំពោះការ ខាតបង់) ។
- គ្មានការដាក់កំហិតលើម្ចាស់កម្មសិទ្ធិជាជនបរទេស (លើកលែងតែកម្មសិទ្ធិដីធ្លី) ។
- នាំមុខប្រទេសចិន ឥណ្ឌា វៀតណាម និងឥណ្ឌូនេស៊ី ចំពោះសេរីភាពសេដ្ឋកិច្ច[1] ។
- ប្រព្រឹត្តស្មើភាពចំពោះអ្នកវិនិយោគទាំងអស់ ។
- នាំមុខប្រទេសហ្វីលីពីន ចិន និងវៀតណាមចំពោះការ ការពារអ្នកវិនិយោគ[2] ។
- គ្មានការត្រួតពិនិត្យតម្លៃលើទំនិញ ឬសេវាកម្ម ។
- គ្មានការត្រួតពិនិត្យលើការប្តូររូបិយវត្ថុបរទេសឬគ្មានការដាក់កំហិតលើការប្តូរប្រាក់ ។
- គ្មានការដាក់កំហិតលើការបង្វិលដើមទុនទៅប្រទេសរបស់ អ្នកវិនិយោគវិញ ។
- ជាប្រទេសដំបូងគេក្នុងចំណោមប្រទេសដែលមានការអភិវឌ្ឍន៍តិច (LDC) ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។
- គ្មានការដាក់កំហិតលើបរិមាណពាណិជ្ជកម្ម បន្ថយរបាំងពន្ធគយ ។ ប្រទេសកម្ពុជាទទួលបានការអនុគ្រោះពន្ធគយ និងកូតាទៅកាន់ទីផ្សារធំៗរបស់ពិភពលោក (ដូចជាសហរដ្ឋអាមេរិក សហភាពអឺរ៉ុប ប្រទេសជប៉ុន និងប្រទេស សមាជិកអាស៊ានជាច្រើនទៀត) ។
- អាជ្ញាធរខេត្តមានសិទ្ធិអំណាចក្នុងការអនុម័តការវិនិយោគ ក្រោមទឹកប្រាក់ ២ លានដុល្លារអាមេរិកដើម្បីជំរុញការ ចាប់ផ្តើមអភិវឌ្ឍអាជីវកម្មអោយបានឆាប់រហ័ស ។

*"ប្រទេសកម្ពុជាកំពុងបើកចំហទាំងស្រុងចំពោះអាជីវកម្ម ហើយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា នឹងព្យាយាមអោយអស់ពីលទ្ធភាព ដើម្បីធានាបាននូវបរិយាកាសអនុគ្រោះ និងភាពជោគជ័យ សម្រាប់រាល់សហគ្រាសទាំងអស់នៅក្នុងប្រទេសកម្ពុជា"* ។

- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

### កម្លាំងពលកម្មតម្លៃទាប និងមានផលិតភាព

ដោយប្រៀបធៀបទៅនឹងអ្នកប្រកួតប្រជែង ជាច្រើននៅក្នុងតំបន់ ប្រទេសកម្ពុជាមានអត្រាប្រាក់ឈ្នួលប្រកួតប្រជែង ហើយកម្លាំងពលកម្មមានផលិតភាពខ្ពស់ ធ្វើអោយប្រទេសកម្ពុជាក្លាយជាទិសដៅដ៏ទាក់ទាញ សម្រាប់ឧស្សាហកម្ម ដែលប្រើប្រាស់កម្លាំងពលកម្មច្រើន ។

កាលពីប៉ុន្មានឆ្នាំថ្មីៗកន្លងទៅនេះ កម្លាំងពលកម្មរបស់ប្រទេសកម្ពុជាបានកើនឡើងជាង ៥០% ច្រើនជាងទ្វេរដងនៃអត្រានៅក្នុងប្រទេសអាស៊ានផ្សេងទៀត[3] ។ដោយមានប្រជាជនវ័យក្មេងច្រើន (ប្រជាជនពាក់កណ្តាលមានអាយុក្រោម ២០ ឆ្នាំ) កម្លាំងពលកម្មនឹងបន្តកើនឡើង ។

1. មូលនិធិបេតិកភណ្ឌ សន្ទស្សន៍សេរីភាពសេដ្ឋកិច្ចឆ្នាំ២០០៩ *http://www.heritage.org/index/*
2. ធនាគារពិភពលោក ស្តីពីការធ្វើអាជីវកម្មឆ្នាំ២០០៩ *http://www.doingbusiness.org/*
3. អង្គការពលកម្មអន្តរជាតិ "ពលកម្ម និងនិន្នាការសង្គមនៅក្នុងអាស៊ាន ឆ្នាំ២០០៧ - សមាហរណកម្ម បញ្ហាប្រឈម និងកាលានុវត្តភាព" ឆ្នាំ២០០៧

### តម្លៃពលកម្មនៅក្នុងឧស្សាហកម្មកាត់ដេរ (ឆ្នាំ២០០៨)

| ប្រទេស | ដុល្លារអាមេរិកក្នុងមួយម៉ោង រួមទាំងបន្ទុកសង្គម |
|---|---|
| ថៃ | 1.29-1.36 |
| ម៉ាឡេស៊ី | 1.18 |
| ចិនដីគោក | 1.08 |
| ចិនតំបន់ឆ្នេរ | 0.86-0.94 |
| ចិនជនបទ | 0.55-0.8 |
| ឥណ្ឌូនេស៊ី | 0.44 |
| វៀតណាម | 0.38 |
| កម្ពុជា | 0.33 |

ប្រភព: Jassin-O'Rourke Group ការវិភាគតម្លៃពលកម្មផលិតសម្លៀកបំពាក់ជាសាកលឆ្នាំ ២០០៨

*"ដូចជាប្រទេសចិន និងឥណ្ឌា នៅក្នុងសម័យកាលមុនៗដែរ ប្រទេសកម្ពុជាត្រូវបានកំណត់ថាជាកន្លែងដែលរំពឹងទុកនៅពេលអនាគត សម្រាប់ការវិនិយោគខាងការផលិត ជាពិសេសដោយសារពលកម្មតម្លៃទាបនិងបុព្វលាភហានិភ័យរបស់ប្រទេសទាប...ប្រទេសកម្ពុជាក៏ទទួលបានអត្ថប្រយោជន៍ពីភាពស្ថិតនៅជិតល្មមទៅនឹងឆ្នេរ ខាងលិចនៃសហរដ្ឋអាមេរិក"* ។

- PriceWaterhouseCoopers.

### ទីតាំងជាយុទ្ធសាស្ត្រក្នុងតំបន់

ប្រទេសកម្ពុជាមានទីតាំងយ៉ាងល្អឥតខ្ចោះ នៅចំចំណុចកណ្តាលតំបន់ ដែលមានថាមពលបំផុតនៅក្នុងពិភពលោក ។ ដោយស្ថិតនៅជាប់ប្រទេសថៃ និងវៀតណាម ប្រទេសកម្ពុជាគឺជាផ្នែករបៀងសេដ្ឋកិច្ចភាគខាងត្បូងនៃមហាអនុតំបន់ទន្លេមេគង្គ លាតសន្ធឹងពីទីក្រុងហូជីមិញដល់ទីក្រុងបាងកក ។

ដោយសារតែទីតាំងយុទ្ធសាស្ត្របែបនេះ ប្រទេសកម្ពុជាទទួលបានការគាំទ្រពីអន្តរជាតិគួរអោយកត់សម្គាល់នៅក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរបស់ខ្លួន ដើម្បីជួយសម្រួលដល់ការធ្វើពាណិជ្ជកម្មនៅក្នុងប្រទេស និងជាមួយប្រទេសជិតខាង ។ ជាលទ្ធផលការធ្វើពាណិជ្ជកម្មជាមួយប្រទេសវៀតណាម និងថៃកំពុងរីកចម្រើនយ៉ាងឆាប់រហ័ស ។




*"អ្នកមានទីក្រុងធំៗបំផុតពីរនៅអាស៊ីអមសងខាងអ្នក ។ អ្នកមានប្រជាជន ១៥ លាននាក់នៅទីក្រុងបាងកក និង ៨ លាននាក់នៅទីក្រុងហូជីមិញ ហើយអ្វីៗនឹងកើតកាន់តែច្រើនឡើងៗចន្លោះទីក្រុងទាំងពីរ ។*

- Edward Hopkins, CB Richard Ellis Group Inc.






# ហេតុអ្វីវិនិយោគនៅខេត្តបាត់ដំបង?

## ១. ទីតាំង - ទីក្រុងនៃភាគពាយព្យ

ខេត្តបាត់ដំបងស្ថិតនៅក្នុងតំបន់ដីដែលសំបូរជីជាតិ ជាប់បឹងទន្លេសាប ។ ខេត្តបាត់ដំបងមានព្រំប្រទល់ជាប់នឹងប្រទេសថៃ ដែលផ្តល់នូវលទ្ធភាពយ៉ាងច្រើន ក្នុងការចូលទៅកាន់ទីផ្សារធំ សម្រាប់ផលិតផលកសិកម្មរបស់ខេត្ត និងមានប្រភពនៃអគ្គិសនីគួរអោយទុកចិត្តផងដែរ ។ ស្រុកចំនួនបួនក្នុងចំណោម ស្រុកទាំង ១៣ របស់ខេត្ត មានព្រំប្រទល់ជាប់ជាមួយប្រទេសថៃ ។

ខេត្តបាត់ដំបងមានហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនល្អប្រសើរ និងជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងដឹកជញ្ជូន ដែលលាតសន្ធឹងលើផ្លូវគោក ចន្លោះរវាងប្រទេសថៃ និងរាជធានីភ្នំពេញ ឆ្ពោះទៅកាន់ប្រទេសវៀតណាម ។ ខេត្តបាត់ដំបងក៏ជាទីក្រុង មជ្ឈមណ្ឌលពាណិជ្ជកម្មដ៏សំខាន់នៃភាគពាយព្យប្រទេសកម្ពុជាផងដែរ ។

### បណ្តាញផ្លូវថ្នល់

ក្រុងបាត់ដំបងមានចម្ងាយពីព្រំដែនថៃតែ ១ ម៉ោងកន្លះប៉ុណ្ណោះ និងពីរាជធានីភ្នំពេញ ៥ ម៉ោង ប្រសិនបើយើងធ្វើដំណើរតាមរថយន្ត ។

ខេត្តបាត់ដំបងតភ្ជាប់ដោយផ្លូវជាតិចំនួន ៣ ដែលមានចម្ងាយជាង ២២០ គ.ម ( ប្រហែល ៥% នៃផ្លូវជាតិសរុបរបស់ប្រទេស) ។

ស្ថានភាពផ្លូវនៅក្នុងខេត្តទាំងមូល ត្រូវបានកែលំអគួរអោយកត់សម្គាល់នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយក្រុមហ៊ុនក្នុងមូលដ្ឋាន បានរាយការណ៍ថាមានការកាត់បន្ថយរយៈពេល និងតម្លៃនៃការដឹកជញ្ជូនរហូតដល់ ៥០% ។ ផ្លូវជាតិលេខ ៥ តភ្ជាប់ពីរាជធានី ភ្នំពេញទៅខេត្តបាត់ដំបង ។ បន្ទាប់ពីកំណាត់ ផ្លូវប្រវែង ១៣០ គ.ម នៃផ្លូវនេះ ត្រូវបានជួសជុលរួចរាល់ធនាគារអភិវឌ្ឍន៍អាស៊ីបានរាយការណ៍ថា មានកំណើននៃការធ្វើចរាចរណ៍ចំនួន ២៤៧% ជាមួយនឹងការកាត់បន្ថយជាមធ្យម ៣៥% នៃថ្លៃដំណើរការដោយយានជំនិះ ។

ពាណិជ្ជកម្មជាមួយប្រទេសថៃត្រូវបានធ្វើការចរាចរណ៍តាមច្រកព្រំដែនចំនួន៤( ១ ច្រកអន្តរជាតិ និង ៣ ច្រកតំបន់) ។

លើសពីនេះទៀត ខេត្តបាត់ដំបងស្ថិតនៅលើផ្លូវជាតិសំខាន់ៗ ពីរគឺផ្លូវជាតិលេខ ៥ និងផ្លូវជាតិលេខ ៥៧ ដែលតភ្ជាប់ទៅកាន់ច្រកព្រំដែនអន្តរជាតិប៉ោយប៉ែត និងប៉ៃលិន ។ ផ្លូវ ទៅកាន់ប៉ៃលិនក្នុងចំណោមផ្លូវផ្សេងទៀតកំពុងត្រូវបានកែលំអ( ក្នុងតម្លៃ៤០លានដុល្លារ) ហើយនឹងបញ្ចប់នៅក្នុងឆ្នាំ ២០១១ ។ ដោយមានការកសាងស្ពានថ្មីប្រវែង ៩២ ម៉ែត្រ នៅជាយក្រុងបាត់ដំបង ការកែលំអនេះនឹងកាត់បន្ថយពេលវេលា និងថ្លៃធ្វើដំណើរ ។

ផ្លូវថ្នល់បានបំរើសេវាយ៉ាងល្អដល់តំបន់ដាច់ស្រយាលរបស់យើងជាច្រើន ។ ក្រៅពីរាជធានីភ្នំពេញ និងខេត្តកណ្តាល ភូមិនៅខេត្តបាត់ដំបងជាមធ្យមមានចម្ងាយមិននៅដាច់ឆ្ងាយពីផ្លូវថ្នល់ ( ៥៤ គ.ម) បើធៀបបណ្តាខេត្តនានានៅកម្ពុជា ។

### ផ្លូវដែក

រាជរដ្ឋាភិបាលកម្ពុជា បានចាប់ផ្តើមធ្វើការជួសជុល ខ្សែផ្លូវដែកពីរាជធានីភ្នំពេញ កាត់តាមខេត្តបាត់ដំបង និងស្វាយស៊ីសុផុន ឆ្ពោះទៅប៉ោយប៉ែតនៅព្រំដែនថៃ ។ ផ្លូវដែកនេះនឹងជួយបង្កើនការដឹកជញ្ជូន និងការធ្វើពាណិជ្ជកម្ម រវាងខេត្តបាត់ដំបងនិងប្រទេសថៃ ព្រមទាំងរាជធានីភ្នំពេញផងដែរ ។

### ផ្លូវទឹក

ក្រុងបាត់ដំបងស្ថិតនៅលើស្ទឹងសង្កែ ដែលហូរមកពីជួរភ្នំក្រវាញ ឆ្ពោះទៅកាន់បឹងទន្លេសាប ។ វាផ្តល់អំណោយផលល្អ សម្រាប់ការធ្វើដំណើរ និងការដឹកជញ្ជូន ស្ទឹងនេះគឺជាចំណុចសំខាន់នៃអត្តសញ្ញាណក្រុង និងជាប្រព័ន្ធដឹកជញ្ជូនតាំងពីយូរណាស់មកហើយ ។ មានការនិយមចូលចិត្តធ្វើដំណើរតាមទូកពីខេត្តសៀមរាបមកខេត្តបាត់ដំបង( ១៥០គ.ម) ពីសំណាក់ភ្ញៀវទេសចរបរទេស "អាចដោយសារតែដងស្ទឹងមានទេសភាពគួរឱ្យគយគន់ និងគួរជាទីចាប់អារម្មណ៍នៅតាមជនបទ"[4] ។

**កម្ពុជា_ខេត្តបាត់ដំបង រយៈពេលធ្វើដំណើរតាមរថយន្តទៅកាន់ទីរួមខេត្តឬក្រុងនានា**




សញ្ញាព្រួញតំណាងឱ្យរយៈពេលនៃការធ្វើដំណើរដោយរថយន្តគិតជាម៉ោងរយៈពេលធ្វើដំណើរទៅកាន់ទីក្រុងបាងកក និង ហូជីមិញ មិនរាប់បញ្ចូលរយៈពេលឆ្លងកាត់ព្រំដែន ។

## ២. ដីមានជីជាតិបំផុតនៃប្រទេសកម្ពុជា

តំណាងអោយប្រហែល ៦,៥% នៃផ្ទៃដីសរុបនៃប្រទេសកម្ពុជា ខេត្តបាត់ដំបងត្រូវបានចាត់ថ្នាក់ថាជាខេត្តមានទំហំមធ្យម ។

គួបផ្សំជាមួយនឹងរបាយទឹកភ្លៀងគ្រប់គ្រាន់ ជំនន់ប្រចាំឆ្នាំ និងមានការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ វាធានាបានថា ដីខេត្តបាត់ដំបងជួយទ្រទ្រង់ដល់វិស័យកសិកម្មកាន់តែរឹងមាំថែមទៀត ។

ខេត្តបាត់ដំបងទាំងមូល មានប្រភេទដីខ្លះសំបូរជីជាតិខ្លាំងបំផុតនៅក្នុងប្រទេសកម្ពុជា ខេត្តមិនត្រឹមតែមានដីល្បាប់នៅជាប់បឹងទន្លេសាបប៉ុណ្ណោះទេ តែក៏មានដីសើមពណ៌ត្នោត និង ដីផ្សេងៗទៀត នៅក្នុងតំបន់នានារបស់ខេត្ត ។

មានទំនប់ធំៗចំនួនបី និងប្រភពទឹកផ្សេងៗ ដែលបំរើដល់ការស្រោចស្រពផ្ទៃដី ២០% របស់ខេត្តទាំងមូល ។

ជាលទ្ធផល ខេត្តបាត់ដំបងគឺជាខេត្តជង្រុកស្រូវរបស់ប្រទេសកម្ពុជា ខេត្តបាត់ដំបងតំណាងអោយដំណាំស្រូវរដូវវស្សាជាង ១០% របស់ប្រទេសកម្ពុជា ( ប្រហែល ៦៧០.០០០ តោន) និងជាកន្លែង ដែលមានរោងម៉ាស៊ីនកិនស្រូវអាជីវកម្មធំបំផុតរបស់ប្រទេស ( ៣៦២. ០០០ តោន) ។ ម៉ាស៊ីនសម្ងួតស្រូវតម្លៃ ៧ លានដុល្លារ នៅក្នុងខេត្តអាចសម្ងួតស្រូវបាន ៣០ តោនក្នុងមួយម៉ោង ដែលលើកស្ទួយដល់សមត្ថភាពកែច្នៃអង្ករបស់ខេត្ត ដ៏គួរអោយកត់សម្គាល់ ។

តែទោះបី ទិន្នផលកសិកម្មរបស់យើង មានភាពសម្បូរបែបមិនមែនត្រឹមតែអង្ករប៉ុណ្ណោះទេ ខេត្តក៏នៅមានភាពល្បីខាងក្រូចពោធិ៍សាត់រសជាតិផ្អែមឆ្ងាញ់ផងដែរ ។ យើងគឺជាខេត្តដែលផលិតពោតធំបំផុតនៅកម្ពុជា ( មានជាងពាក់កណ្តាលនៃដំណាំពោតសរុបប្រចាំឆ្នាំ) ហើយយើងក៏ដាំដុះ សណ្តែកសៀង សណ្តែកបាយ ដំឡូងមី សណ្តែកដី និងផ្លែឈើហូបផ្លែក្នុងបរិមាណយ៉ាងច្រើនផងដែរ (រួមមាន ស្វាយ ខ្នុរ ចេក និង ម្នាស់) ។កសិករដាំ

4. មូលនិធិបេតិកភណ្ឌ សន្ទស្សន៍សេរីភាពសេដ្ឋកិច្ចឆ្នាំ២០០៩ *http://www.heritage.org/index/*





## ពីជាតិដីខ្ពស់របស់ខេត្តបាត់ដំបង




ប្រភព : Cambodia Atlas, Danida

ដំឡូងមីមួយចំនួន នៅក្នុងខេត្តបានរាយការណ៍ឱ្យដឹងថា ពួកគាត់ទទួលបានទិន្នផល ៤០ តោន ក្នុង ១ ហិកតារ ។ ប្រហែល ២ ភាគ ៣ នៃបរិមាណដំឡូងធ្វើការនាំចេញទៅប្រទេសជិតខាង គឺប្រទេសថៃ ។ កប្បាស ដែលដាំនៅក្នុងខេត្តបាត់ដំបង ត្រូវបាននាំចេញទៅប្រទេសចិន ។

### ទិន្នន័យដំណាំសំខាន់ៗ នៅក្នុងខេត្តបាត់ដំបង ឆ្នាំ ២០០៨-២០០៩:

| ដំណាំផ្សេងៗ | បរិមាណផលិត (គិតជាពាន់តោន) | ធៀបទៅនឹងបរិមាណសរុប (%) |
|---|---|---|
| ពោតក្រហម | 432.9 | 69.2 |
| សណ្តែកសៀង | 42.0 | 38.7 |
| សណ្តែកខៀវ | 17.4 | 45.1 |
| ដំឡូងមី | 1.265.0 | 34.4 |
| សណ្តែកដី | 3.6 | 14.2 |
| ល្ង | 6.5 | 23.9 |
| ដំឡូងជ្វា | 4.0 | 10.1 |
| បន្លែចំរុះ | 15.8 | 06.0 |

ប្រភព: របាយការណ៍ប្រចាំឆ្នាំ ២០០៨-២០០៩-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

យើងរំពឹងថានឹងបន្តពង្រីក មូលដ្ឋានកសិកម្មរបស់យើងជាបន្ត ដោយវិនិយោគមួយផ្នែកបន្ថែមលើប្រព័ន្ធធារាសាស្ត្រ ។ ការវិនិយោគនេះ មានគម្រោងស្តារធារាសាស្ត្រភាគពាយព្យរបស់ AFD/ADB ដែលមានតម្លៃ ៦៤ លានដុល្លារ ។

ទោះបីផ្ទៃដីប្រហែលមួយភាគបីនៃខេត្ត គឺជាដី ព្រៃក៏ដោយ ខេត្តនៅមានដីសម្រាប់ធ្វើកសិកម្ម ។ដីល្អដែលនៅជាប់ផ្លូវធំនិងតំបន់ដែលមានប្រព័ន្ធស្រោចស្រពមានតម្លៃប្រហែល ២០.០០០ ដុល្លារ ក្នុង ១ ហិកតា (២ ដុល្លារ/១ម២) ចំណែកដីថោកជាងនេះ មានតម្លៃពី ៣.០០០ដុល្លារទៅ៥.០០០ដុល្លារក្នុង១ហិកតា ។ក្នុងក្រុងបាត់ដំបងដីមានតម្លៃប្រហែលពី ១០០ ដុល្លារ ទៅ ៦០០ ដុល្លារ/ ម២ ។

## ៣. ទីផ្សារធំបំផុតទីពីររបស់ប្រទេសកម្ពុជា

ក្រុងបាត់ដំបង គឺជាក្រុងធំបំផុតទីពីរនៃប្រទេសកម្ពុជា ដែលមានប្រជាជនជាង ១៥០.០០០នាក់ ។

ក្រុងបាត់ដំបងមានវិស័យសេវាកម្មទូលំទូលាយ និងច្រើនប្រភេទ ដែលគាំទ្រដល់ការធ្វើពាណិជ្ជកម្មជាមួយប្រទេសថៃ និងមានរោងចក្រកសិកម្មជុំវិញ ។ ប្រជាជនមួយភាគធំធ្វើការនៅក្នុងវិស័យសេវាកម្មក្នុងខេត្តបាត់ដំបង (៣៧%) ច្រើនជាងខេត្តផ្សេងទៀតនៅក្នុងប្រទេសកម្ពុជាក្រៅពីរាជធានីភ្នំពេញ ។

សាខាធនាគារជាតិកម្ពុជាមួយ និងធនាគារឯកជនចំនួនប្រាំពីរ កំពុងធ្វើប្រតិបត្តិការនៅក្នុងក្រុងបាត់ដំបង ព្រមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុជាច្រើនទៀត ។ ខេត្តបាត់ដំបងតំណាងអោយ៦%នៃកម្ចីរបស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជា និងតំណាងអោយ ៥% នៃអ្នកដាក់ប្រាក់ក្នុងធនាគារ ។

មានមន្ទីរពេទ្យចំនួន ៤ នៅក្នុងខេត្ត រួមជាមួយនឹងគ្លីនិក ឯកជនចំនួន ៦ និងមណ្ឌលសុខភាពស្រុកចំនួន ៧៥ ។

ជាខេត្តមួយដ៏សម្បូរសប្បាយ ខេត្តបាត់ដំបងមានកម្រិតភាពក្រីក្រទាបជាងខេត្តផ្សេងៗ ។ ជាលទ្ធផល ប្រជាជនខេត្តដំបងមួយចំនួនមានចំណូល សម្រាប់ចំណាយតាមជម្រើស ដែលធ្វើអោយខេត្តបាត់ដំបងក្លាយជាទីផ្សារក្នុងស្រុក ដ៏រីកលូតលាស់បំផុតមួយ នៅក្នុងប្រទេសកម្ពុជា ។ ជាឧទាហរណ៍ នៅក្នុងខេត្តបាត់ដំបងមានរោងចក្រខ្នាតតូច ផលិតទឹកបរិសុទ្ធ ចំនួន ១៣ កន្លែង ។

ជាសញ្ញាមួយនៃកំណើន និងសក្តានុពលរបស់ខេត្ត ជាទីផ្សារក្នុងស្រុក ក្រុមហ៊ុនដ៏ធំរបស់ប្រទេសជប៉ុន គឺ តូយ៉ូតា បានប្រកាសថា ក្រុមហ៊ុននឹងបើកអគារតាំងបង្ហាញម៉ូតរថយន្តមួយខេត្តបាត់ដំបង ។

## ៤. កម្លាំងពលកម្ម - ច្រើន មានវ័យក្មេង មានការអប់រំ មានតម្លៃពលកម្មទាប

ក្រៅពីរាជធានីភ្នំពេញ ខេត្តបាត់ដំបងគឺជាខេត្ត ដែលមានប្រជាជនច្រើនជាងគេបំផុតមួយនៃប្រទេសកម្ពុជា ។ កម្លាំងពលកម្មរបស់យើងមានវ័យក្មេង មានចំណាប់អារម្មណ៍ខ្លាំងលើការងារ និងមានការអប់រំ ។ ដោយប្រជាជន ៤៣% អាយុក្រោម ១៨ ឆ្នាំក្នុងចំណោមប្រជាពលរដ្ឋជាង១លាននាក់ កម្លាំងពលកម្មនេះនឹងបន្តកើនឡើង ។

អត្រាចុះឈ្មោះចូលរៀនថ្នាក់មធ្យមសិក្សា និងអក្ខរកម្ម ស្ថិតនៅក្នុងចំណោមកម្រិតខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ។ យើងមានសិស្សជាង ២៦៥.០០០ នាក់ ដែលបានចូលរៀននៅសាលាបឋមសិក្សាចំនួន ៥៥១ របស់យើង និងអនុវិទ្យាល័យ និងវិទ្យាល័យរបស់យើងចំនួន ១០៤ ។ មានសាលារៀនឯកជនចំនួន ៣៨ ទៀតផងដែរ ។

| គ្រឹះស្ថានអប់រំ | ចំនួន |
|---|---|
| មត្តេយ្យសាលា | 134 |
| សាលាបឋមសិក្សា | 551 |
| អនុវិទ្យាល័យ | 83 |
| វិទ្យាល័យ | 21 |
| សាលាឯកជន | 38 |
| សាកលវិទ្យាល័យ | 9 |
| សាលាគរុកោសល្យ | 2 |
| សាលាបណ្តុះបណ្តាល ភាសាបរទេស | 2 |
| វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ | 3 |





សាកលវិទ្យាល័យចំនួនប្រាំបួន ក្នុងនោះមានសាកលវិទ្យាល័យ រដ្ឋ ១ និងសាកលវិទ្យាល័យឯកជនចំនួន ៨ កំពុងដំណើរការនៅក្នុងខេត្ត រួមជាមួយនឹងសាលាគរុកោសល្យចំនួនពីរ និង មជ្ឈមណ្ឌលបណ្តុះបណ្តាលភាសាបរទេសចំនួនពីរ។ លើសពីនេះទៀត វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈចំនួនបីកំពុងបង្រៀន ជំនាញជួសជុលរថយន្ត គ្រឿងចក្រ កសិកម្ម អគ្គិសនី និងអេឡិចត្រូនិក រចនាក្រាហ្វិក បដិសណ្ឋារកិច្ច និងជំនាញផ្សេងៗទៀតជាច្រើន។ លើសពីនេះទៀត ខេត្តបាត់ដំបងមានសាលាសិល្បៈដ៏ល្បីមួយរបស់ អង្គការហ្វាពន្លឺសិល្បៈ។

សាកលវិទ្យាល័យបាត់ដំបងដែលជាសាកលវិទ្យាល័យរបស់រដ្ឋ មាននិស្សិតជាង១.៥00នាក់កំពុងសិក្សាថ្នាក់បរិញ្ញាប័ត្រ និង បរិញ្ញាប័ត្រជាន់ខ្ពស់ ក្នុងឆ្នាំសិក្សា ២00៩។

ខ្ទង់ចំណាយទៅលើការអប់រំបឋមសិក្សា ដែលជាចំណែកមួយ នៃផលទុនសរុបក្នុងស្រុកបានកើនឡើងគួរអោយកត់សម្គាល់ នៅក្នុងប្រទេសកម្ពុជា នាពេលប៉ុន្មានឆ្នាំថ្មីៗនេះ ហើយនៅពេលនេះ អាចប្រៀបធៀបគ្នាបានជាមួយប្រទេសថៃ។ ហើយការចំណាយលើការអប់រំសម្រាប់ខេត្តបាត់ដំបង ក៏មិនខុសគ្នាដែរ។ រាជរដ្ឋាភិបាលមានផែនការបន្តបង្កើនថវិកាចំណាយលើវិស័យអប់រំ។

ដោយសារប្រព័ន្ធអប់រំរបស់យើងមានភាពរឹងមាំ វាគ្មានអ្វីគួរអោយព្រួយបារម្ភឡើយ កម្លាំងពលកម្មរបស់ខេត្តបាត់ដំបង មានការកើនឡើងខ្លាំង ក្នុងនោះ ៤៥% ធ្វើការនៅក្នុងវិស័យ ឧស្សាហកម្ម និងសេវាកម្ម – ដែលជាអត្រាខ្ពស់បំផុតនៅក្នុងប្រទេសកម្ពុជា ក្រៅពីរាជធានីភ្នំពេញ។

កម្មករគ្មានជំនាញនៅខេត្តបាត់ដំបងទាមទារថ្លៃពលកម្ម ប្រហែល ពី ៥0 ទៅ ៩0 ដុល្លារក្នុង ១ ខែ (បូកទាំងអាហារ និងកន្លែង ស្នាក់នៅក្នុងករណីខ្លះ)។ កម្មករជំនាញ និងមានបទពិសោធន៏ច្រើន មានតម្លៃពលកម្មរហូតដល់ ១៨0 ដុល្លារក្នុង ១ ខែ។

យើងមានមោទនភាព ដែលមានធនធានមនុស្សឈានមុខបែបនេះ ដើម្បីគាំទ្រអាជីវកម្មរបស់យើង ហើយជឿថា នេះគឺជាគុណសម្បត្តិប្រកួតប្រជែងខ្លាំងបំផុតមួយរបស់យើង-សូមអនុញ្ញាតឱ្យប្រជាជនរបស់យើងជួយអភិវឌ្ឍសហគ្រាសរបស់អ្នក។

## ៥. ការផ្គត់ផ្គង់អគ្គិសនីប្រកបដោយការប្រកួតប្រជែង

ខេត្តបាត់ដំបងមានអគ្គិសនីគ្រប់គ្រាន់ ដែលមានតម្លៃថោក និងអាចទុកចិត្តបាន។ យោងតាមក្រុមហ៊ុនក្នុងស្រុក ការដាច់ចរន្តកម្រកើតឡើងណាស់។ ការផ្គត់ផ្គង់គ្រប់គ្រាន់នេះត្រូវបានរំពឹងថា នឹងកើនឡើងនៅពីរបីឆ្នាំខាងមុខ។

ទីតាំងខេត្តបាត់ដំបងនៅជាប់ប្រទេសថៃ ធ្វើអោយយើងមានអគ្គិសនីគ្រប់គ្រាន់ និងមានតម្លៃថោក។ ស្រុកចំនួនបី និងក្រុងមួយ ទទួលបានការផ្គត់ផ្គង់អគ្គិសនី ដែលនាំចូលមកពីប្រទេសថៃ។ ខ្សែបញ្ជូនចរន្តអគ្គិសនីថ្មីៗតពីព្រំដែនថៃ តាមផ្លូវជាតិលេខ ៥ មកកាន់ខេត្តបាត់ដំបង នឹងត្រូវសម្រេចរួចរាល់ នៅក្នុងឆ្នាំ ២00៩ ហើយនឹងពង្រីងការផ្គត់ផ្គង់នេះ។

វិសាលភាពបណ្តាញកំពុងពង្រីក ជាមួយនឹងការកសាងខ្សែបញ្ជូនតង់ស្យុងមធ្យមពីទីរួមខេត្ត ដើម្បីផ្គត់ផ្គង់តំបន់ជុំវិញ ក្នុងចម្ងាយ ៤0 គ.ម ដែលឧបត្ថម្ភដោយកម្ចីពីធនាគារពិភពលោក។

លើសពីនេះទៀត ចាប់ពីឆ្នាំ ២0១២ ទៅខេត្តបាត់ដំបងនឹងទទួលបានអគ្គិសនី ដែលផលិតដោយរោងចក្រវារីអគ្គិសនីថ្មីមួយ នៅខេត្តពោធិ៍សាត់។ ក្នុងរយៈពេលនេះ ខេត្តបាត់ដំបងក៏នឹងត្រូវតភ្ជាប់ទៅបណ្តាញអគ្គិសនីកម្ពុជា ដែលពង្រីកអោយធំផងដែរ។

បច្ចុប្បន្ននេះ អគ្គិសនីនៅក្រុងបាត់ដំបងមានតម្លៃ ១.000 រៀលក្នុង ១ គីឡូវ៉ាត់ម៉ោង (ប្រហែល 0,២៥ ដុល្លារ អាមេរិក ក្នុង ១ គីឡូវ៉ាត់ម៉ោង)។

## ៦. ទេសចរណ៍

ខេត្តបាត់ដំបងបានក្លាយជាគោលដៅកាន់តែមានប្រជាប្រិយភាព សំរាប់ភ្ញៀវទេសចរជាតិ និង អន្តរជាតិ។ នៅក្នុងក្រុងមានវត្តនិងព្រះវិហារជាច្រើន ព្រមទាំងស្ថាបត្យកម្មតាមរចនាបថអាណានិគមបារាំងដែលបានអភិរក្សយ៉ាងល្អដូចជា សាលាខេត្ត ផ្សារ សាលារៀន និង ផ្ទះដែលមើលឃើញទេសភាពដងស្ទឹង។

តំបន់នៅជុំវិញក្រុងមានប្រាសាទបុរាណជាច្រើន ដែលសាងសង់ចន្លោះសតវត្សរ៍ទី១0 និង ទី១១។ ប្រាសាទទាំងនេះមានប្រាសាទភ្នំបាណន់ ភ្នំសំពៅ ប្រាសាទឯកភ្នំ ប្រាសាទស្ទឹង ប្រាសាទបាសែត...។ល។ ក្រៅពីនោះ យើងក៏មានរមណីយដ្ឋានទេសចរណ៏ជាច្រើនក្នុងនោះមាន: រមណីយដ្ឋានវប្បធម៌-ធម្មជាតិ រមណីយដ្ឋានបែបសាសនា រមណីយដ្ឋានប្រវត្តិសាស្ត្រ រមណីយដ្ឋានកែច្នៃ ភូមិវប្បធម៌....។ល។ ដែលសរុបមានចំនួន ៣៦ កន្លែង។ ជាពិសេសយើងមានតំបន់ទេសចរណ៏ធម្មជាតិ ព្រែកទ័ល ដែលជាដែនជំរកសត្វស្លាបទឹក និងឋបនីយជីវមណ្ឌលដ៏មានសារៈប្រយោជន៏ ដល់ការបន្តពូជរបស់ពពួកជីវចម្រុះរាប់លានប្រភេទនៅអាស៊ីអាគ្នេយ៏ (ផ្ទៃក្រឡាទំហំ ជាង ៣១.000 ហិកតារ)។ លើសពីនេះទៀតកំពីងពួយក៏ជាបឹងទំនប់កំសាន្តមួយ ដែលមានការនិយមចូលចិត្តពីប្រជាជននៅក្នុងខេត្ត។

ហេតុនេះហើយ ទើបមានការសាងសង់សណ្ឋាគារ និងផ្ទះសំណាក់ ថ្មីៗជាច្រើននៅខេត្តបាត់ដំបងក្នុងរយៈពេលពីរឆ្នាំចុងក្រោយនេះ ក្នុងនោះមានសណ្ឋាគារធំបំផុត មានបន្ទប់ចំនួន ១៣៦ សាលសន្និសីទ អាងហែលទឹក និងបន្ទប់ហាត់ប្រាណ។

*"... ជាក្រុងមាត់ស្ទឹងដ៏ស្រស់សង្ហារ ជាកន្លែងបណ្តុំ ស្ថាបត្យកម្មសម័យបារាំង ដែលបានអភិរក្សល្អបំផុតនៅក្នុងប្រទេស និងមានប្រជាជនរួសរាយរាក់ទាក់ និងផ្តល់ភាពកក់ក្តៅ។ ... ជាមូលដ្ឋានដ៏អស្ចារ្យសំរាប់ទស្សនាប្រាសាទ និងភូមិដ៏ស្រស់ស្អាតនៅជិតៗនោះ។"*

- Lonely planet ឆ្នាំ 2007

## ៧. ធនធានធម្មជាតិមិនទាន់ប្រើប្រាស់

ខេត្តបាត់ដំបងមានដែនគំរបព្រៃឈើចំនួន ៥៨៥.៥៥0 ហិកតារ (ផែនទីគំរបព្រៃឈើឆ្នាំ២00២) ដែនជំរកសត្វភ្នំសំកុស ចំនួន ៣៣៣.៧៥0 ហិកតារ (ដែលលាតសន្ធឹងដល់ពោធិ៏សាត់ និង កោះកុង) ដែនជំរកសត្វព្រៃរនាមដូនសំ ចំនួន៤0,0២១ ហិកតារ (ស្ថិតនៅជាប់ខេត្តបន្ទាយមានជ័យ) តំបន់ប្រើប្រាស់ច្រើនយ៉ាង សំឡូត ចំនួន៦0,000 ហិកតារ ព្រមទាំងមានជីវមណ្ឌលបឹងទន្លេសាប ចំនួន៣១៦,២៥0ហិកតារ (គិតទាំងខេត្តបាត់ដំបង កំពង់ឆ្នាំង ពោធិ៏សាត់ និងសៀមរាប)។

ទន្ទឹមការផ្តោតការយកចិត្តទុកដាក់ទៅលើ ការធានានូវការប្រើប្រាស់ធនធានធម្មជាតិរបស់ប្រទេសដោយចិរភាព ខេត្តបាត់ដំបងមានសក្តានុពលរុករករ៉ែគួរអោយកត់សម្គាល់។ រ៉ែមានតម្លៃជាច្រើនមាននៅក្នុងតំបន់នេះ មានដូចជា មាស ដែក អាលុយមីញ៉ូម ផ្ទូស្វាត ថ្មកំបោរ និងត្បូងមានតម្លៃជាច្រើន។

# វិស័យសំខាន់ៗរបស់ខេត្ត

## កសិកម្ម

ដូចបានរៀបរាប់ពីខាងលើរួចហើយ ខេត្តបាត់ដំបងមានសក្តានុពលលើវិស័យកសិកម្ម ដោយផ្អែកលើកត្តាធនធានធម្មជាតិ ធនធានមនុស្ស ដីជាតិដី ព្រមទាំងប្រព័ន្ធ ធារាសាស្ត្រ ,,, ។ល។





ក្រៅពីដំណាំផលល្វានុផល ខេត្តបាត់ដំបងក៏មានចិញ្ចឹមបសុសត្វជាច្រើនផងដែរ។ យើងមានកសិដ្ឋានចិញ្ចឹមជ្រូក ១៩ កន្លែង (៥,៦២២ ក្បាល) កសិដ្ឋានចិញ្ចឹមមាន់សាច់ ៤២ កន្លែង (១៩,២០០ ក្បាល) កសិដ្ឋានមាន់យកពង ៦ កសិដ្ឋានចិញ្ចឹមទា ១២៨ កន្លែង (១៧០,៥០០ ក្បាល) និង កសិដ្ឋានចិញ្ចឹមសត្វពាហនៈ ៨ កន្លែង (ប្រភពៈ ទិន្នន័យមន្ទីរ កសិកម្មខេត្ត ឆ្នាំ ២០០៩)។

ផលនេសាទប្រចាំឆ្នាំរបស់ខេត្តបាត់ដំបងមានប្រហែល ៦.០០០ តោន ដោយគិតរួមទាំងផលពីវារីវប្បកម្ម ៥២០ តោន។

## ឧស្សាហកម្ម និងសេវាកម្ម

ភាពជោគជ័យរបស់យើងលើការគាំទ្រអាជីវកម្ម យ៉ាងសកម្មខ្លាំងក្លា និងរស់រវើកបានធ្វើអោយខេត្តបាត់ដំបង ក្លាយជាគោលដៅឈានមុខគេ សម្រាប់សហគ្រាសនានា នៅក្នុងប្រទេស។ *ខេត្តបាត់ដំបងត្រូវបានទទួលស្គាល់ថាជាខេត្ត ដែលមមាញឹកខាងផ្នែកពាណិជ្ជកម្ម ដែលមានក្រុមហ៊ុនជាច្រើនបានចុះឈ្មោះ ហើយកំពុងដំណើរការ។ ជាក់ស្តែង ក្នុងចន្លោះពីឆ្នាំ ២០០៨ មកដល់ ខែសីហា ឆ្នាំ២០០៩ ពាណិជ្ជករបានមកសុំចុះបញ្ជីបង្កើតក្រុមហ៊ុនចំនួន ៤១ សាខាក្រុមហ៊ុនចំនួន ១៣ និង សហគ្រាសចំនួន ១០។ ក្រៅពីនោះ ក៏មានអាជីវកម្មខ្នាតតូចមួយចំនួនធំមានៈ ប្រភេទពាណិជ្ជកម្មចំនួន៩១ ប្រភេទសេវាកម្ម ចំនួន៤០ ប្រភេទសិប្បកម្មចំនួន២២០ និង ប្រេងឧស្ម័នចំនួន ១៣។*

បច្ចុប្បន្ននេះ យើងមានមោទនភាពដែលមានសហគ្រាសឯកជន ចំនួនជាង ៦.០០០ ដែលកំពុងដំណើរការនៅក្នុងខេត្តបាត់ដំបង រួមមាន៖

| សកម្មភាព | ចំនួនសហគ្រាស |
|---|---|
| រោងម៉ាស៊ីនកិនស្រូវ | 340 |
| រោងចក្រផលិតឥដ្ឋ | 39 |
| សិប្បកម្មផ្សេងៗ | 88 |
| សំណង់ | 20 |
| សិប្បកម្មផលិតមី | 13 |
| រោងចក្រខ្នាតតូចផលិតទឹកសុទ្ធ | 13 |
| សិប្បកម្មផលិតស្រាទំពាំងបាយជូ | 1 |
| រោងចក្រខ្នាតតូចផលិតទឹកកក | 22 |
| សិប្បកម្មកែច្នៃត្រី | 3 |
| សិប្បកម្មផលិត គ្រឿងឧបភោគ និងបរិភោគផ្សេងៗ | 15 |
| ភោជនីយដ្ឋាន និងអាហារដ្ឋាន | 1.708 |
| ហាងជួសជុល | 632 |
| សេវាវិជ្ជាជីវៈ | 113 |
| រោងចក្រកែច្នៃកប្បាស (ជាសំឡី) | 1 |
| សិប្បកម្មចំណីសត្វ | 1 |
| សេវាផ្សេងៗ | 412 |
| សិប្បកម្មកែច្នៃឈើ | 5 |
| សម្ភារៈសេរ៉ាមិច | 7 |
| គ្រឿងសង្ហារិម | 17 |
| សិប្បកម្មផ្សេងៗ | 74 |
| សម្ភារៈសំណង់ | 38 |
| ហាងលក់ដុំ | 17 |
| ហាងលក់រាយគ្រឿងទេស | 972 |
| ហាងលក់រាយផ្សេងទៀត | 1.805 |
| សាកវប្បកម្ម/ដំណាំផ្ទះកញ្ចក់ | 57 |
| ការចិញ្ចឹមសត្វ | 26 |

*ប្រភព ៖ មូលនិធិអាស៊ី និង IFC ការចុះបញ្ជីគ្រឹះស្ថានអាជីវកម្មនៅទីរួមខេត្ត និងតំបន់ទីក្រុងដែលបានជ្រើសនៅប្រទេសកម្ពុជា ខែមីនា ឆ្នាំ២០០៩*

ជាក់ស្តែង នាពេលបច្ចុប្បន្នខេត្តបាត់ដំបងមានម៉ាស៊ីនកិនស្រូវ ចំនួន ៣៤០រោងម៉ាស៊ីន។ ម្ចាស់រោងម៉ាស៊ីនកិនស្រូវ របស់យើងនាំចេញអង្ករទៅប្រទេសដូចជា បារាំង ថៃ វៀតណាម និងម៉ាឡេស៊ី ។ រោងម៉ាស៊ីនកិនស្រូវទាំងនេះ ក៏កំពុងទទួលបានការបញ្ជាទិញពីទ្វីបអាហ្វ្រិក អឺរ៉ុប ប្រទេសចិន (ហុងកុង) និងសិង្ហបុរីផងដែរ។

ដោយមានការជឿនលឿនផ្នែកបច្ចេកវិទ្យា និងដោយសារតែតំលៃប្រេងឡើងខ្ពស់ធ្វើឱ្យសហគ្រិនម៉ាស៊ីនកិនស្រូវមានគំនិតច្នៃប្រឌិត ដែលបានប្តូរពីការប្រើប្រេងម៉ាស៊ូតទៅប្រើថាមពលជីវម៉ាស (ប្រើអង្កាមដុតធ្វើជាប្រេង) កែច្នៃម៉ាស៊ីន។ រហូតមកដល់ឆ្នាំ២០០៩នេះ មានម៉ាស៊ីនកិនស្រូវ១២រោងម៉ាស៊ីនដែលដើរដោយជីវម៉ាស។

រោងចក្រកែច្នៃធំមួយកំពុងសាងសង់នៅក្នុងខេត្តបាត់ដំបង។ រោងចក្រនេះនឹងធ្វើការកែច្នៃ និងវេចខ្ចប់អង្ករ ពោត សណ្តែក និងផលិតផលកសិកម្មផ្សេងៗ ហើយរំពឹងថានឹងមានសមត្ថភាពកែច្នៃ និងវេចខ្ចប់បានរហូតដល់ ៣០ តោន ក្នុង ១ ម៉ោង។

ខេត្តបាត់ដំបងក៏មានក្រុមហ៊ុនផ្គត់ផ្គង់ចំណីសត្វ គ្រឿងចក្រ កសិកម្ម និងជីកសិកម្ម ឡឥដ្ឋ សិប្បកម្មគ្រឿងសង្ហារិម និង ឧស្សាហកម្មខ្នាតតូចផ្សេងៗទៀតកំពុងដំណើរការផងដែរ។

## កាលានុវត្តភាពអាជីវកម្ម

ខេត្តរបស់យើងផ្តល់នូវកាលានុវត្តភាពជាច្រើនដល់អាជីវកម្មថ្មីៗ ដូចមានបញ្ជាក់តាមប្រភេទក្រុមហ៊ុនជាច្រើន ដែលបានកំពុងដំណើរការទីនេះរួចហើយ។ យើងមើលឃើញកាលានុវត្តភាពធំ សម្រាប់អោយក្រុមហ៊ុនដើម្បីទាញយកអត្ថប្រយោជន៍ពីចំណុចខ្លាំង ប្រកបដោយការប្រកួតប្រជែងរបស់យើងតាមរយៈការវិនិយោគបន្ថែមទៀតលើ៖

**កសិកម្ម** យើងមានដីសំបូរជីជាតិច្រើន មានកំលាំងពលកម្មសំរាប់ធ្វើកសិកម្ម និងមានហេដ្ឋារចនាសម្ព័ន្ធគាំទ្រ។ ជាក់ស្តែង យើងមានតំបន់ដីព្រៃតិចតួច ដែលត្រៀមធ្វើជាដីសម្បទានសំរាប់ក្រុមហ៊ុនសមស្របណា ដែលអាចវិនិយោគលើផ្នែកកសិកម្ម និងកសិ-ឧស្សាហកម្ម។

**កសិ-ពាណិជ្ជកម្ម** ជាពិសេស ការកែច្នៃចំណីអាហារ។ យើងមានលទ្ធភាពដែលសំខាន់ចាំបាច់ដើម្បីបន្ថែមតម្លៃទៅលើ ទិន្នផលកសិកម្មដ៏ច្រើន និងទិន្នផលចម្រុះមុខរបស់យើង។ ទោះបីជាសមត្ថភាពកិនស្រូវគួរអោយកត់សម្គាល់ក៏ដោយ នៅតែមានលទ្ធភាពសម្រាប់សមត្ថភាពបន្ថែមទៀតដល់ដំណាំស្រូវនាំចេញមិនទាន់កែច្នៃ។ អ្នកប្រកបអាជីវកម្មក្នុងស្រុកជឿថាកាលានុវត្តភាពល្អសំរាប់ការផលិតចំណីសត្វ ជី ដំឡូងមី ពោត សណ្តែក ផ្លែឈើ និងត្រីផងដែរ (ត្រី ៦.០០០ តោនចាប់ជារៀងរាល់ឆ្នាំ)។ វិនិយោគិនជនជាតិកូរ៉េម្នាក់មានគម្រោងវិនិយោគលើការកែច្នៃពោតរបស់យើង។

**កម្មន្តសាល** រួមមាន ឧស្សាហកម្មកាត់ដេរ ដែលគាំទ្រដោយ កម្លាំងពលកម្មមានតម្លៃទាប ហេដ្ឋារចនាសម្ព័ន្ធល្អ មានទីតាំងនៅជិតប្រទេសថៃ និងបរិយាកាសគាំទ្រដល់អាជីវកម្ម។

**ទេសចរណ៍** សំដៅជាពិសេសទៅលើទេសចរណ៍ធម្មជាតិ និងកសិ-ទេសចរណ៍។ ចំនួនភ្ញៀវទេសចរមកកាន់ប្រទេសកម្ពុជាកាន់តែច្រើនឡើងៗ ក្នុងមួយឆ្នាំ ហើយក៏មានភ្ញៀវទេសចរច្រើនឡើងៗមកទស្សនាខេត្តបាត់ដំបងផងដែរ។ ដោយសារតែផ្លូវថ្នល់មានភាពប្រសើរល្អបានធ្វើឱ្យមានការកើនឡើងនៃភាពទាក់ទាញ និងជួយសំរួលដល់ការធ្វើដំណើរចេញចូលខេត្តបាត់ដំបង។ វាផ្តល់ឱកាសជាច្រើនដល់ការប្រកបអាជីវកម្មរួមទាំងអាជីវកម្មភោជនីយដ្ឋានទំនើបលំដាប់ខ្ពស់ជាដើម។

**សេវាកម្ម** ដើម្បីទ្រទ្រង់ដល់មូលដ្ឋានគ្រឹះកសិកម្ម និងឧស្សាហកម្មរបស់យើងដែលកំពុងរីកលូតលាស់ ព្រមទាំងវិស័យទេសចរណ៍ផងដែរ។ ហើយផ្តល់លទ្ធភាព ដល់អាជីវកម្មថ្មីៗជាច្រើនលើវិស័យសេវាកម្ម។

មានកាលានុវត្តភាពល្អនៅក្នុងស្រុកមួយចំនួន ដែលនៅជាប់នឹង ប្រទេសថៃ ជាពិសេសនៅពេលផ្លូវថ្នល់ និងការផ្គត់ផ្គង់អគ្គិសនីបន្តការកែលំអ។

## សកម្មភាពអភិវឌ្ឍន៍កំពុងដំណើរការ

ទោះបីជាយើងមានមោទនភាពចំពោះសមិទ្ធផលរបស់យើងក៏ដោយ យើងនៅតែបន្តពង្រឹងនិងកែលំអភាពទាក់ទាញនៃការវិនិយោគ។ យើងនៅតែមានភាពសកម្ម ក្នុងការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអាជីវកម្ម និងទាក់ទាញសហគ្រាសអាជីវកម្មឈានមុខអោយមកធ្វើអាជីវកម្មនៅក្នុងខេត្តរបស់យើង។ រដ្ឋបាលខេត្តបាត់ដំបងបានផ្តោតអាទិភាពលើចំណុចដូចខាងក្រោមដើម្បីពង្រឹងបរិយាកាសអាជីវកម្ម និងវិនិយោគបន្ថែមទៀត នៅក្នុងខេត្ត :

- អភិវឌ្ឍផ្លូវថ្នល់ និងផ្លូវដែក
- ស្តារឡើងវិញ និងអភិវឌ្ឍប្រព័ន្ធធារាសាស្រ្ត
- លើកទឹកចិត្តដល់ការរុករករ៉ែ
- ទាក់ទាញការវិនិយោគផ្នែកកសិកែច្នៃ
- ជំរុញគ្រឿងម៉ាស៊ីន និងបច្ចេកទេសកសិកម្មអោយទំនើប
- អភិវឌ្ឍទេសចរណ៍ធម្មជាតិ
- អភិវឌ្ឍតំបន់តាមព្រំដែនថៃ ។

ការអភិវឌ្ឍសំខាន់ៗផ្សេងទៀត កំពុងដំណើរការ រួមមាន :

- យុទ្ធសាស្រ្តសមាហរណកម្មពាណិជ្ជកម្មវិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា: នៅក្នុងកម្មវិធីនេះ ផលិតផលជាច្រើនរបស់ខេត្តបាត់ដំបងទទួលបានការគាំទ្របន្ថែម។ ផលិតផលដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្រ្តនេះ រួមមាន សម្លៀកបំពាក់ ស្បែកជើង កម្មន្តសាលការដឹកជញ្ជូន នឹង ទេសចរណ៍។ ការជួយគាំទ្ររួមមាន ការសម្របសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ការវិនិយោគ កំណែទម្រង់ច្បាប់ និងការកសាងសមត្ថភាពគ្រប់គ្រង ព្រមទាំងសមត្ថភាពជំនាញថ្នាក់មូលដ្ឋាន។
- ដៃគូអភិវឌ្ឍន៍ជាច្រើន បានជួយដល់ការអភិវឌ្ឍន៍វិស័យឯក ជនរបស់ខេត្តបាត់ដំបង នៅក្នុងឧស្សាហកម្មសំខាន់ៗ ដូចខាង ក្រោម :

| គម្រោង | ដៃគូអភិវឌ្ឍន៍ | វិស័យ |
| --- | --- | --- |
| គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជា (USAID Cambodia MSME) | USAID | ផ្នែកឥដ្ឋក្បឿង វារីវប្បកម្ម ជ្រូក ទឹកស្អាត និងអនាម័យ ផ្លែឈើ ទឹកឃ្មុំ ជ័រទឹក ផ្នែកឧស្សាហកម្មកាត់ដេរ និង ទេសចរណ៍ |
| ការបង្កើនការយល់ដឹង និងការគ្រប់គ្រងជីដីស្រូវ | ACIAR | ស្រូវ |
| ការស្រាវជ្រាវប្រព័ន្ធដាំដុះសម្រាប់ពិពិធកម្មដំណាំនៅក្នុងប្រទេសកម្ពុជានិងអូស្រ្តាលី | ACIAR | ដំណាំខ្ពង់រាបក្រៅពីស្រូវ |
| គម្រោងផ្សព្វផ្សាយកសិកម្មកម្ពុជា អូស្រ្តាលីដំណាក់កាលទី ២ | AusAID | កសិកម្ម |
| គម្រោងសេវាព័ត៌មានទីផ្សារកសិកម្ម (CAMIS) | CIDA | ផ្លែឈើ និងបន្លែ |
| គម្រោងស្តារធារាសាស្រ្តភាគពាយ័ព្យ | AFD / ADB | ការស្រោចស្រព |
| គម្រោង អភិវឌ្ឍន៍កសិកម្មក្នុងតំបន់រងគ្រោះដោយមីននៅកម្ពុជា | ADMAC | កសិកម្ម |
| គំរោងស្តារឡើងវិញលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចនៅបណ្តាខេត្តតំបន់ពាយព្យកម្ពុជា | ECOZONE | សេដ្ឋកិច្ច និង សង្គមកិច្ច |
| គំរោងលើកកំពស់សេវាកម្មផ្សព្វផ្សាយកសិកម្ម | JICA | កសិកម្ម |

## ត្រូវការស្វែងយល់បន្ថែមទៀតទេ?

សំរាប់ព័ត៌មានបន្ថែមស្តីអំពីឱកាសវិនិយោគនិងការអភិវឌ្ឍន៍ នៅក្នុងខេត្តបាត់ដំបង សូមទាក់ទង :

សាលាខេត្តបាត់ដំបង
ទូរស័ព្ទ/ទូរសារ: (+855) 053 952141

www.battambang.gov.kh

**លោក: ពាង ណារិទ្ធ**
អគ្គលេខាធិការ សាលាខេត្តបាត់ដំបង
ទូរស័ព្ទដៃ: (+855) 16 824 870 រឺ 92 909 870

narith_peang@gmail.com

សភាពាណិជ្ជកម្មខេត្តបាត់ដំបង
(+855) 53 953 908

bcc@camshin.com.kh

**www.investincambodia.com**

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា - គណៈកម្មាធិការវិនិយោគកម្ពុជា
ទូរស័ព្ទ : (+855) 23 981 154

**www.cambodiainvestment.gov.kh**

វិទ្យាស្ថានជាតិ ស្ថិតិ
www.nis.gov.kh

**ក្រសួងជាតិនានា:**
ក្រសួងពាណិជ្ជកម្ម
www.moc.gov.kh
ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
www.mef.gov.kh
ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
www.mine.gov.kh
ក្រសួង ការងារនិង បណ្តុះបណ្តាល វិជ្ជាជីវៈ
www.nlv.gov.kh
ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
www.mlmupc.gov.kh
ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
www.mptc.gov.kh
ក្រសួងសាធារណការ និង ដឹកជញ្ជូន
www.mpwt.gov.kh
ក្រសួងទេសចរណ៍
www.mot.gov.kh
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
www.maff.gov.kh

**ផ្សេងៗ:**
សមាគមរោងចក្រកាត់ដេរនៅកម្ពុជា
www.gmac-cambodia.org
វេទិកាវិស័យឯកជន-រដ្ឋាភិបាល
www.cambodia-gpsf.org
សភាពាណិជ្ជកម្មភ្នំពេញ
www.ppcc.org.kh

| ដីនៅខេត្តបាត់ដំបង |
| --- |
| ប្រភេទ: នៅតំបន់ជាប់នឹងបឹងទន្លេសាប គឺជាដីល្បប់បឹង តំបន់ផ្សេងទៀត គឺជាដីសើមពណ៌ត្នោត និងជាដីសីលាល្បប់ ដីគ្មានជីជាតិ និងដីសើមពណ៌ ប្រផេះ ។ |
| កម្រិតជីជាតិ : ខ្ពស់ |

| ព័ត៌មានសង្ខេបពីខេត្តបាត់ដំបង | |
|---|---|
| ប្រជាជន :(ជំរឿនប្រជាជនទូទៅ 2008) | 1.025.174 |
| អាយុ ពី 15-64 | 57% |
| សមាមាត្រការងារផ្នែកកសិកម្ម : | 90% |
| ចំណាត់ថ្នាក់ភាពក្រីក្ររបស់ខេត្ត : | 8/24 |
| ផ្ទៃដី : | 11.748 Km$^2$ |
| ដង់ស៊ីតេប្រជាជន :<br>(% នៃមធ្យមភាគជាតិ) | 88 នាក់/គីឡូម៉ែត្រការ៉េ<br>116% |
| ចំនួនក្រុង/ស្រុក : | ក្រុង1 និង 13ស្រុក |
| ចំនួនឃុំ/សង្កាត់ : | 86 ឃុំ និង 10សង្កាត់ |

| អត្រាពន្ធកម្ពុជា | | |
|---|---|---|
| ពន្ធលើប្រាក់ចំណេញ | ធម្មតា | 20% |
| | អត្រាលើកទឹកចិត្ត | 0% ឬ 9% |
| ពន្ធអប្បបរមា | | 1% នៃផលរបរ |
| ពន្ធកាត់ទុក | | 15% |
| ប្រាក់ចំណូលពីការជួលអចលនវត្ថុ | | 10% |
| ការបង់ប្រាក់ជូនអនិវាសនជន | | 14% |
| ពន្ធលើប្រាក់បៀវត្សរ៍ (រៀលក្នុងមួយខែ) | | |
| 0-500,000 | | 0% |
| 500,001-1,250,000 | | 5% |
| 1,250,001-8,500,000 | | 10% |
| 8,500,001-12,500,000 | | 15% |
| 12,500,001 + | | 20% |
| អនិវាសនជន | អត្រាថេរ | 20% |
| ពន្ធលើផលបន្ទាប់បន្សំ | | 20% |
| ពន្ធលើតម្លៃបន្ថែម | | 10% |
| | នាំចេញ | 0% |
| ពន្ធលើការផ្ទេរសិទ្ធិអចលនវត្ថុ | | 4% |

| ទិន្នន័យម៉ាក្រូសេដ្ឋកិច្ចកម្ពុជា | 2005 | 2006 | 2007 | 2008 |
|---|---|---|---|---|
| កំណើន GDP (%) | 13.5 | 10.8 | 9.6 | 5.5 |
| កំណើននាំចេញ (%) | 12.4 | 26.9 | 10.7 | 8.8 |
| ការនាំចេញ (% of GDP) | 64.2 | 68.0 | 66.7 | 68.8 |
| វិនិយោគផ្ទាល់ពីបរទេស<br>FDI (លានដុល្លារ) | 375 | 475 | 867 | 790 |
| វិនិយោគផ្ទាល់ពីបរទេស<br>FDI (% of GDP) | 6.0 | 6.5 | 6.9 | 6.0 |

## ថ្លៃអាជីវកម្ម

| ដី | លក់ (ក្នុងមួយម៉ែត្រការ៉េ) |
|---|---|
| រាជធានីភ្នំពេញ | $350-$2,000 |
| ដីពាណិជ្ជកម្ម | $30-$200 |
| តំបន់ផ្សេងៗ | $4-$50 |
| ជនបទ | $0.50-$5 |

| ទីតាំងការិយាល័យ | ថ្លៃឈ្នួលក្នុងមួយខែ |
|---|---|
| សំខាន់ | $9-11/មួយម៉ែត្រការ៉េ |
| បន្ទាប់បន្សំ | $6-8/មួយម៉ែត្រការ៉េ |
| ថ្លៃឈ្នួលរោងចក្រ | $1.50-$2.50/មួយម៉ែត្រការ៉េ ក្នុងមួយខែ |
| ថ្លៃឈ្នួលឃ្លាំង | $1.00-$2.50/មួយម៉ែត្រការ៉េ ក្នុងមួយខែ |

| ថ្លៃអគ្គិសនីនៅរាជធានីភ្នំពេញ (លើកលែងតំបន់សេដ្ឋកិច្ចពិសេស) | | |
|---|---|---|
| | គីឡូវ៉ាត់ម៉ោងក្នុង ១ ខែ) | តម្លៃ (រៀលក្នុង ១ គីឡូវ៉ាត់ម៉ោង |
| ឧស្សាហកម្ម | <45,000 | 600 |
| | 45,000-130,000 | 550 |
| | >130,000 | 500 |
| | តង់ស្យុងមធ្យម | 480 |
| ពាណិជ្ជកម្ម | <45,000 | 650 |
| | 45,000-130,000 | 600 |
| | >130,000 | 500 |
| | តង់ស្យុងមធ្យម | 480 |
| ការផ្គត់ផ្គង់ហ្គាសដល់ឧស្សាហកម្ម | | $0.32/គ.ក្រ |

| តម្លៃពលកម្ម | ប្រាក់បៀវត្សរ៍ ដុល្លារក្នុងមួយខែ |
|---|---|
| អ្នកចាត់ការជាន់ខ្ពស់ | 1,000-1,500 |
| អ្នកចាត់ការមធ្យម | 500-1,000 |
| អ្នកចាត់ការកម្រិតដំបូង | 240-400 |
| គណនេយ្យករ | 250-400 |
| លេខាធិការ | 120-150 |
| ស្មៀនការិយាល័យ | 100-120 |
| អ្នកបើកបរ | 100-120 |
| អ្នកយាម | 50-80 |
| កម្មករ | 50-80 |
| ប្រាក់បៀវត្សរ៍អប្បបរមាសម្រាប់<br>កម្មកររោងចក្រកាត់ដេរ | 60 |

# ខេត្តបាត់ដំបង

# សក្តានុពលវិនិយោគ



Photographs by Nathan Horton www.nathanhortonphotography.com

Designed by DESIGNGROUP www.dgcambodia.com